| | *១.ប្រទេសដែលបានធ្វើសកម្មភាពល្អមុនឆ្នាំ១៩៩០* | ៣ |
| | *២.ប្រទេសដែលមិនទាន់ធ្វើសកម្មភាពមុនឆ្នាំ ១៩៩០* | ៣ |
| | *៣.ការលើកឡើងនៃសកម្មភាពនៅប្រទេសអាស៊ីប៉ាស៊ីភិច* | ៤ |
| | ២.៣-ការបូកសរុបផែនការសកម្មភាពស្តីពីថ្នាំជក់ ឬសុខភាពសំរាប់ឆ្នាំ ១៩៩៥-១៩៩៩ | ៤ |
| ៣ | សភាពការណ៍ថ្នាំជក់នៅកម្ពុជា | ៤ |
| | ៣.១ ការប្រើប្រាស់ថ្នាំជក់នៅកម្ពុជា | ៤ |
| | ៣.២ សកម្មភាពជំរុញថ្នាំជក់ | ៥ |
| ៤ | ច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាលដើម្បីគ្រប់គ្រងថ្នាំជក់ | ៦ |
| | ៤.១ សកម្មភាពត្រួតពិនិត្យការជក់ បារី | ៦ |
| | ៤.២ រចនាសម្ព័ន្ធពន្ធដារ | ៧ |
| ៥ | ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃថ្នាំជក់ក្នុងកម្ពុជា | ៨ |
| | ៥.១ អំណះអំណាងផ្សេងៗគ្នា | ៨ |
| | ៥.២ ជម្ងឺ និងមរណភាពដែលបង្កដោយការប្រើប្រាស់ថ្នាំជក់ ១.០០០តោន | ៨ |
| | ៥.៣ តំលៃខាតបង់ | ១០ |
| | ៥.៤ ផលចំណេញ | ១០ |
| | ៥.៥ ការប៉ាន់ស្មានតំលៃខាតបង់ និងផលចំណេញផ្សេងៗគ្នា | ១០ |
| | *១.ទិដ្ឋភាពទី១* | ១១ |
| | *២.ទិដ្ឋភាពទី២* | ១២ |
| | *៣.ទិដ្ឋភាពទី៣* | ១៣ |
| ៦ | សេចក្តីសន្និដ្ឋាន | ១៤ |
| ៧ | សំណូមពរ | ១៥ |
| | ៧.១ យុទ្ធនាការគ្រប់គ្រងថ្នាំជក់ | ១៥ |
| | ៧.២ ការអប់រំសុខភាព ឬការលើកកំពស់យល់ដឹង | ១៥ |
| | ៧.៣ គោលនយោបាយថ្លៃ (ពន្ធ, ពន្ធលើតំលៃបន្ថែម) | ១៥ |
| | ៧.៤ និតិកម្ម | ១៥ |
| | ៧.៥ ស្ថាប័នសំរបសំរួល | ១៥ |

# អារម្ភកថា

សុខភាពគឺជាវត្ថុដែលមានតំលៃបំផុតក្នុងជីវិតមនុស្ស ។ ប្រទេសមួយដែលមានប្រជាជនមានសុខភាពល្អ គឺជាប្រទេសដែលមានការអភិវឌ្ឍន៏និងវឌ្ឍនភាព ។ នៅពេលដែលប្រជាជនមានសុខភាពល្អទាំងកាយទាំងប្រាជ្ញាគេអាចធ្វើការផលិតកម្មជាច្រើនសំរាប់ជីវភាពរបស់គេ និង សំរាប់ជាតិ ។

ការជក់ថ្នាំ គឺជាបុព្វហេតុសំខាន់មួយនៃមរណភាពដែលអាចការពារបានពីជំងឺមហារីកសួត ។ ថ្នាំជក់ក៏ជាមូលហេតុទាក់ទងទៅនឹងជំងឺមហារីកដទៃទៀតរួមមាន : ជំងឺមាត់ អណ្តាត បំពង់ ដង្ហើម ច្រមុះ បំពង់អាហារ តំរងនោម លំពែង និងក្រលានហើយក៏ជាកត្តាគ្រោះថ្នាក់នៃបំពង់ក ។ ការជក់បារីគឺជាមូលហេតុចំបងចំពោះជំងឺផ្លូវដង្ហើម និងសរសៃឈាមជុំវិញ ។ មានជំងឺកាន់តែច្រើនឡើងដែលត្រូវបានគេទទួលស្គាល់ថា ទាក់ទងទៅនឹងការ ប្រើប្រាស់ថ្នាំជក់ ។

ជាតិណាកូទីនក្នុងថ្នាំជក់មានជាតិញៀនយ៉ាងខ្ពស់ ។ ថ្នាំជក់ត្រូវបានគេចាត់ថ្នាក់ថាជាប្រភេទថ្នាំញៀនមួយ នៅក្រោមការចាត់ថ្នាក់ជំងឺអន្តរជាតិលំដាប់ទី១០ ។ ដំណើរការដែលសំរេច ភាពញៀនរបស់ថ្នាំជក់ គឺដូចគ្នាទៅនឹងការសំរេចចំពោះថ្នាំញៀនដទៃទៀត រួមទាំងថ្នាំញៀន ខុសច្បាប់ផងដែរ ។

"ថ្នាំជក់ ឬសុខភាព " គឺជាសកម្មភាពចំបងមួយរបស់កម្មវិធី WHO ដោយសារថា ទូទៅត្រូវបានគេដឹងថាថ្នាំជក់ធ្វើអោយសុខភាពខ្សោយ ។ វាបង្កអោយមានជំងឺសួត ហើយអាចធ្វើអោយកុមារនិងប្រជាជននៅជុំវិញមានគ្រោះថ្នាក់ ។ ថ្នាំជក់គឺជាការគំរាម កំហែងដ៏ធ្ងរអោយ ភ័យខ្លាចដល់បែបផែនជីវភាពដ៏សុខដុមរម្យនាក្នុងពិភពឧស្សាហកម្មទំនើប និងក្នុងប្រទេសកំពុងអភិវឌ្ឍន៏ ។ បញ្ហាថ្នាំជក់ក្នុងតំបន់អាស៊ីប៉ាស៊ីភិចនឹងនាំទៅដល់វិនាសកម្ម ខាងសុខភាពប្រសិនបើគ្មានសកម្មភាពដើម្បីត្រួតត្រាការប្រើប្រាស់ថ្នាំជក់ទេ ។

នៅពេលដែលប្រទេសនានានៅក្នុងពិភពលោកខិតខំត្រួតពិនិត្យថ្នាំជក់ ដោយឡែកនៅកម្ពុជា ថ្នាំជក់បានជំរុញយ៉ាងខ្លាំងក្លាតាមរយៈការផ្សាយពាណិជ្ជកម្ម ដោយមានវិធានការត្រួត ពិនិត្យតិចតួចនៅឡើយ ។ រោងចក្របារីជាច្រើនត្រូវបានគេផ្តល់លិខិតអនុញ្ញាតិ និងលើកទឹកចិត្ត ។ ការពង្រីកផលិតកម្មត្រូវបានធ្វើសំរាប់ការប្រើប្រាស់ក្នុងស្រុក និងនាំចេញ ទៅប្រទេសជិតខាងដូចជា វៀតណាម និងឡាវ នៅពេលដែលបារីថ្មីៗជាច្រើនបាននាំចូល និងដាក់លក់នៅតាមទីផ្សារទាំងឡាយ ។

មកដល់ពេលនេះមិនទាន់មានការសិក្សាស្តីអំពីផលប៉ះពាល់នៃថ្នាំជក់ ដើម្បីវាយតំលៃផលប៉ះពាល់ដល់សេដ្ឋកិច្ចនៅឡើយទេ ។ ដោយហេតុនេះហើយការសិក្សានេះមានសារសំខាន់ យ៉ាងខ្លាំងសំរាប់រដ្ឋាភិបាល ដើម្បីពិចារណា រកវិធីគ្រប់គ្រងការប្រើប្រាស់ថ្នាំជក់អោយមាន ប្រសិទ្ធភាព ។

ការសិក្សានេះផ្អែកលើទិន្នន័យដែលទទួលបានដោយការធ្វើសម្ភាសជាមួយទីភ្នាក់ងាររដ្ឋាភិបាល វេជ្ជបណ្ឌិត និង ស្ថាប័នពាក់ព័ន្ធដទៃទៀតដើម្បីវាយតំលៃសភាពការណ៏ប្រើប្រាស់ថ្នាំជក់ និងគូសបញ្ជាក់អោយឃើញផលប៉ះពាល់ដ៏ធ្ងន់ធ្ងររបស់ ថ្នាំជក់ទៅលើសង្គមនិងសេដ្ឋកិច្ច ។ ទិន្នន័យចាស់ៗ ប្រមូលពីរបាយការណ៏ការសិក្សា និងការអង្កេតពីមុនក៏ត្រូវបានប្រើប្រាស់ ដើម្បីបូកសរុបខ្លឹមសារដែល ទាក់ទងដល់ថ្នាំជក់ និងដើម្បីគណនាផលប៉ះពាល់ទៅលើសេដ្ឋកិច្ច ។

ការគណនាត្រូវបានផ្អែកលើការខាតបង់ខាងសេដ្ឋកិច្ចនៃថ្នាំជក់នៅកម្ពុជា ។ ការខាតបង់ខាងសេដ្ឋកិច្ចសំដៅទៅការខាតបង់ផ្ទាល់ និងការខាតបង់ប្រយោល ។ ការខាតបង់ផ្ទាល់រួមមាន ការចំណាយលើការថែទាំសុខភាព ចំណាយលើការព្យាបាល និងការពារដោយបុគ្គល រដ្ឋ និងអង្គការនានាចំពោះជំងឺដែលកើតមានឡើងដោយការជក់ថ្នាំ ។ ចំណែកការខាតបង់ប្រយោល គឺសំដៅទៅតំលៃនៃការបាត់បង់ផលិតកម្មអាស្រ័យដោយពិការភាព និងការស្លាប់មុនអាយុ ។ ការគណនាត្រូវបានផ្អែកលើផលិតផលសង្គមសរុប (GDP) ក្នុងន័យ "ការប្រៀបធៀបកំលាំងទិញ" (PPP) ។ ការស្លាប់មុនអាយុនៃជំងឺបណ្តាលមកពីថ្នាំជក់ត្រូវបានប៉ាន់ស្មានថា បាត់បង់អស់១៥ឆ្នាំជាមធ្យម ។ ការប៉ាន់ប្រមាណត្រូវធ្វើដោយកំណត់យកអត្រាអប្បហារ (Discount rate) ៥ % ។

**គោលបំណងនៃការស្រាវជ្រាវគឺដើម្បី :**

១. បូកសរុប

- សភាពការណ៍ថ្នាំជក់នៅកម្ពុជា
- គោលនយោបាយរដ្ឋាភិបាល និតិកម្មដើម្បីត្រួតពិនិត្យថ្នាំជក់

២. វាយតំលៃការបាត់បង់ខាងសេដ្ឋកិច្ចនៃថ្នាំជក់នៅកម្ពុជា ទាក់ទងនឹងការបាត់បង់ផលិតកម្មឬការខាតបង់ប្រយោលនៅពេល ដែលមានជំងឺ និងការស្លាប់មុនអាយុ ។

៣. ផ្តល់យោបល់សំរាប់ផែនការសកម្មភាពសំរាប់ត្រួតពិនិត្យថ្នាំជក់ ។

យើងខ្ញុំសង្ឃឹមថា ការសិក្សានឹងជួយផ្តល់ចំណេះដឹង និងព័ត៌មានជាមូលដ្ឋានដល់ រដ្ឋាភិបាល និងអ្នកធ្វើសេចក្តីសំរេច ដើម្បីពិចារណារកគោលនយោបាយដែលអាចធ្វើបាន ដើម្បីរៀបចំច្បាប់គ្រប់គ្រងថ្នាំជក់នៅកម្ពុជា ។

អ្នកនិពន្ធសូមទទួលខុសត្រូវទាំងស្រុងចំពោះការប៉ាន់ស្មានការវិភាគខ្លឹមសារ និងទស្សនៈដែលបញ្ជាក់ក្នុងការសិក្សានេះ ។

ចាប សុថារិទ្ធ        លឹម ថៃភាង        ប៉ូ សំណាង

# ផលប៉ះពាល់ខាងផ្នែកសេដ្ឋកិច្ចនៃថ្នាំជក់
# ក្នុងកម្ពុជា : ការប៉ាន់ស្មានដំបូង

*ទាច សុផារិទ្ធ*

*ឈឹម ផុំភាង*

*ប៉ូ សំណាង*

---

## សង្ខេប

ការខាតបង់ខាងសេដ្ឋកិច្ចនៃថ្នាំជក់នៅកម្ពុជារួមមាន : ការខាតបង់ផ្ទាល់នៃការការពារនិងព្យាបាល និង ការ ខាតបង់ប្រយោលដល់សេដ្ឋកិច្ច ។ ទោះបីជាមានការលំបាកដើម្បីប្រមែប្រមូលទិន្នន័យដោយសារស្ថិតិនៅកម្ពុជានៅមានកំរិត និង មិនទាន់សុក្រិត្យ ការវិភាគតាមទិន្នន័យជាលើកដំបូងបានបញ្ជាក់ថា ចំនួនប្រជាជនដែលស្លាប់ដោយសារថ្នាំជក់នៅឆ្នាំ ១៩៩៧ មានប្រហែល ៥.៨០០នាក់ ។ ការប៉ាន់ប្រមាណបានបញ្ជាក់ថា បើគ្មានការការពារដ៏មានប្រសិទ្ធភាព និងការផ្លាស់ប្តូរឥរិយាបទទេ ការបង់ខាតប្រហែល ១.០៧៩លានដុល្លា និងប៉ះពាល់ដល់សេដ្ឋកិច្ចនៅឆ្នាំ ២០០៧ ។ ចំនួនអ្នកស្លាប់ បន្តបន្ទាប់សរុបក្នុង ១ទសវត្សអាចកើនដល់ ៧៣.៥២៦នាក់ ។ តំលៃខាតបង់ប្រយោលដល់សេដ្ឋកិច្ចអាស្រ័យ ដោយការស្លាប់មុន អាយុជាមធ្យម ១៥.០០០ដុល្លាក្នុងមនុស្សម្នាក់ ។ ចន្លោះឆ្នាំ ១៩៩៧-២០០៧ តំលៃបច្ចុប្បន្ននៃការបង់ខាតប្រយោលដោយមានអ្នកស្លាប់ដោយថ្នាំជក់អាចនៅចន្លោះ ៩៥០លានដុល្លា ទៅ១.០៧៩លានដុល្លា ។ ប្រសិនបើមានការផ្លាស់ប្តូរឥរិយាបទ និងការប្រឹងប្រែងការពារដ៏មានប្រសិទ្ធភាពពីវិស័យឯកជន និងសាធារណៈ ការប៉ាន់ប្រមាណផ្សេងទៀតបានបញ្ជាក់ថា នៅឆ្នាំ ២០០៧ មានការស្លាប់ថយចុះ ៩.៨៩៩នាក់ និងបន្ថយការខាតបង់សេដ្ឋកិច្ចបាន ១២៥លានដុល្លា ។

## ១~សេចក្តីផ្តើម

គេទទួលស្គាល់ថា ថ្នាំជក់បំផ្លាញសុខភាព ។ វាបង្កអោយមានជំងឺមហារីកសួត រលាកផ្លូវដង្ហើម រលាកផ្លូវអាហារ និង ជំងឺសរសៃឈាម និងអាចបង្កគ្រោះថ្នាក់ដល់កុមារ ។ ថ្នាំជក់គឺជាការគំរាមកំហែងដ៏ធំបំផុតចំពោះ បែបផែនជីវិតនិងសុខភាពក្នុងពិភពឧស្សាហកម្ម និងកំពុងកើនឡើងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែរ ។ បញ្ហាថ្នាំជក់នៅ ក្នុងតំបន់នឹងកាន់តែធ្ងន់ធ្ងរទៅៗគេប៉ាន់ស្មានថា ការប្រើប្រាស់ថ្នាំជក់ក្នុងតំបន់កើនឡើង ១៥ ៍ ចន្លោះឆ្នាំ ១៩៨៨-១៩៩២ ហើយការលក់ថ្នាំជក់បានកើនឡើងនៅទ្វីបអាស៊ី ៣៣ ៍ ចន្លោះឆ្នាំ ១៩៩១-២០០០(17) ។

ជាការពិតរាល់មួយតោននៃថ្នាំជក់បង្កអោយមនុស្សប្រហែល ០១នាក់ស្លាប់ ។ ជាទូទៅ អ្វីដែលគេមិនសូវនឹង នោះគឺថ្នាំជក់បង្កវិនាសកម្មសេដ្ឋកិច្ច ។ អ្នកជក់និងអ្នកផលិតបានផលចំណេញពីថ្នាំជក់ខ្លះគឺរីករាយមួយភ្លែតៗ និងប្រាក់ចំណេញពីការលក់ដែលអាចប៉ាន់ស្មានបានពីទិន្នន័យទីផ្សារ ប៉ុន្តែផលចំណេញទាំងនេះត្រូវបានបំផ្លាញដោយថ្លៃខាត ដោយសារជម្ងឺ និង មរណភាពបណ្តាលមកពីថ្នាំជក់ ។

---

ផ្ទុយពីនេះទៅទៀត តំបន់ប៉ាស៊ីហ្វិកខាងលិច គឺជាតំបន់ដែល WTO តែមួយគត់ដែលការប្រើប្រាស់បារី កំពុងកើនឡើង ។ ការកើនឡើងនៃមរណភាពដោយថ្នាំជក់ ត្រូវបានគេរំពឹងថានឹងកើនឡើងកាន់តែខ្លាំងនៅប៉ុន្មានទសវត្សក្រោយៗទៀត ។ គេប៉ាន់ស្មានថ្មីៗនេះថា ប្រជាជនលើពិភពលោកស្លាប់ប្រហែល ៣លាននាក់ក្នុងមួយឆ្នាំដោយសារថ្នាំជក់ ។ ហើយការស្លាប់នេះអាចកើនឡើងដល់ទៅ ១០លាននាក់នៅឆ្នាំ ២០២៥ ។ គេប៉ាន់ស្មានថាក្នុងចំណោម ១០លាននាក់ នោះមាន៧លាននាក់ ជាអ្នកស្លាប់នៅបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ យ៉ាងហោចណាស់ ២លាននាក់នៅ ប្រទេសចិន ។(14)

នៅពេលណាដែលប្រទេសភាគច្រើនក្នុងពិភពលោកខិតខំត្រួតត្រាការប្រើប្រាស់ថ្នាំជក់នៅក្នុងកម្ពុជាថ្នាំជក់បែជា កំពុងត្រូវបានគេផ្សព្វផ្សាយ និងជំរុញយ៉ាងខ្លាំងក្លា ។ សព្វថ្ងៃនេះមានរោងចក្រផលិតបារីចំនួន ១២បានទទួលការអនុញ្ញាត ឱ្យផលិត ។ ការពង្រឹងផលិតកម្មបានធ្វើឡើងដើម្បីផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក និងសំរាប់ការនាំចេញទៅប្រទេសជិតខាងដូចជា វៀតណាម និងឡាវ ។ បារីបរទេសម៉ាកថ្មីៗជាច្រើនក៏បាននាំចូលយ៉ាងខ្លាំងក្លាដែរ ។

## ២_ការបូកសរុបខ្លឹមសារ

ចន្លោះឆ្នាំ ១៩៩១-២០០០ឧស្សាហកម្មថ្នាំជក់ត្រូវបានគេព្យាករណ៍ថានឹងកើនឡើងនៅទ្វីបអាស៊ី ៣៣% ។ ការប្រើប្រាស់ថ្នាំជក់ បានកើន ១៥ % នៅចន្លោះឆ្នាំ ១៩៨៨-១៩៩២(16) ។ អង្គការសុខភាពបានគូសបញ្ជាក់កត្តាសំខាន់ៗ ៧ ដែលរួមចំណែកបង្កើនការប្រើប្រាស់ថ្នាំជក់ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកខាងលិចគឺ :

១-ការកើនឡើងនៃប្រជាជន

២-ការកើនឡើងនៃចំណូល

៣-ការកើនឡើងនូវចំនួនស្ត្រីដែលចាប់ផ្ដើមទេះជក់បារី

៤-ការខ្វះខាតការយល់ដឹងពីគ្រោះថ្នាក់នៃថ្នាំជក់

៥-ការផ្សាយពាណិជ្ជកម្មនិងជំរុញថ្នាំជក់

៦-ការខ្វះខាតទុន និងការគាំទ្រសមស្របសំរាប់វិធានការត្រួតពិនិត្យ

៧-ការលំបាកក្នុងការអនុវត្តវិធានការគ្រប់គ្រងថ្នាំជក់ ជាពិសេសចំពោះប្រជាជននៅតំបន់ជនបទដាច់ស្រយាល ។

ដោយហេតុថាកត្តានីមួយៗទាក់ទងផ្ទាល់ដល់សភាពការណ៍កម្ពុជាបច្ចុប្បន្ន ប្រទេសកម្ពុជានឹងជួបប្រទះការកើនឡើងនៃថ្នាំជក់នៅប៉ុន្មានឆ្នាំខាងមុខនេះ ប្រសិនបើគ្មានវិធានការតឹងរ៉ឹងដើម្បីអភិវឌ្ឍន៍ និងគាំទ្រវិធានការគ្រប់គ្រងថ្នាំជក់ ។

ការជក់មានផលប៉ះពាល់ដល់កុមារនិងធ្វើឱ្យយឺតយ៉ាវក្នុងការជាសះស្បើយពីការវះកាត់ ។ ផ្សែងបារីបង្កគ្រោះថ្នាក់យ៉ាងខ្លាំង ព្រោះកំទេចល្អិតៗវាអាចចូលដល់បំពង់ខ្យល់ក្នុងសួត ។ ការសិក្សាខ្លះបានរកឃើញថាជម្ងឺហឺតមានភាពធ្ងន់ធ្ងរចំពោះកុមារដែលឪពុកម្ដាយគេជក់ ៤៧ % ខ្ពស់ជាងកុមារដែលឪពុកម្ដាយមិនជក់ ។ ការសិក្សាមួយរកឃើញថា អ្នកជម្ងឺដែលជក់ថ្នាំទៀងទាត់មុនពេលវះកាត់ មានការប្រថុយនៃការគ្រោះថ្នាក់ដំបៅក្លាយពីរដងធៀបជាមួយអ្នកជម្ងឺដែលមិនធ្លាប់ជក់បារី ។

## ២.១_ការប្រើប្រាស់ថ្នាំជក់ពិភពលោក

អង្គការស្បៀងអាហារនិងកសិកម្ម (FAO) បានប៉ាន់ស្មានថា ការប្រើប្រាស់ថ្នាំជក់ត្រូវបានគេរំពឹងថាកើនឡើង ជាង ៥០ ៖ ពីឆ្នាំ ១៩៧៧-១៩៩៥ ។ ការកើនឡើងនេះនឹងកើតមាននៅប្រទេសកំពុងអភិវឌ្ឍន៍ កន្លែងដែលមានការប្រើប្រាស់ទ្វេរមួយជាពីរ ។ នៅក្នុងប្រទេសអភិវឌ្ឍន៍ ការប្រើប្រាស់ថ្នាំជក់ បានធ្លាក់ចុះពីឆ្នាំ ១៩៧៥ ដល់ ១៩៩៥ ។

*តារាង ១ ការប្រើប្រាស់ថ្នាំជក់ពិភពលោក (ពាន់តោន)*

| តំបន់ | ១៩៧៥ | ១៩៨៥ | ១៩៩៥ |
|---|---|---|---|
| កំពុងអភិវឌ្ឍន៍ | ២៣០០ | ៣៧០០ | ៥៤០០ |
| អភិវឌ្ឍន៍ | ២៤០០ | ២៣០០ | ២៣០០ |
| ពិភពលោក | ៤៧០០ | ៦០០០ | ៧៣០០ |

*ប្រភព (FAO)*

## ២.២ការបូកសរុបនៃផែនការសកម្មភាពស្តីពីថ្នាំជក់ ឬសុខភាពសំរាប់ឆ្នាំ១៩៩០_១៩៩៤

ផែនការសកម្មភាព WHO ស្តីពី "ថ្នាំជក់ ឬ សុខភាព" សំរាប់ឆ្នាំ ១៩៩០-១៩៩៤ បានទាក់ទងដល់សកម្មភាពតាមប្រទេសនិងតំបន់ដូចខាងក្រោមនេះ :

- ដើម្បីអភិវឌ្ឍន៍ និងអនុវត្តគោលនយោបាយ និងកម្មវិធីជាតិស្វែងយល់មួយស្តីពីការគ្រប់គ្រងថ្នាំជក់ ។
- ដើម្បីប្រមូលទិន្នន័យណាដែលមិនទាន់មាន ជាពិសេសអត្រារាលដាល និងតំលៃនៃការប្រើប្រាស់ថ្នាំជក់ ។
- ដើម្បីការអភិវឌ្ឍន៍ការអប់រំសុខាភិបាល និងប្រព័ន្ធពត៌មានថែមទៀត ។
- ដើម្បីព្រៀង និងអនុវត្តច្បាប់សមស្រប និង
- ដើម្បីអនុវត្តគោលនយោបាយថ្លៃ

តារាងសំនួរមួយត្រូវបានគេបញ្ជូនទៅតំណាច់ខែ មករា ១៩៩៤ ទៅរដ្ឋាភិបាល និងសមាជិកនៃក្រុមការងារដើម្បីវាយតំលៃការរីកចំរើនក្នុងការអនុវត្តផែនការ ។ ចំលើយត្រូវបានគេទទួលពី ២០ក្នុងចំណោម ៣៥ប្រទេសក្នុងតំបន់ ។ ខាងក្រោមនេះគឺជាការសង្ខេបនៃលទ្ធផលរបស់អង្កេតនោះ ។

*១.ប្រទេសដែលបានធ្វើសកម្មភាពល្អមុនឆ្នាំ១៩៩០*

ប្រទេសនិងតំបន់ខ្លះដូចជា អូស្ត្រាលី ហុងកុង ញូវស៊ីលែន និងសិង្ហបុរី បានធ្វើសកម្មភាពល្អមុនពេលចាប់ផ្តើមផែនការសកម្មភាព ១៩៩០ ទៅទៀតហើយបានធ្វើអោយមានការថយចុះនូវការរាលដាលនៃថ្នាំជក់ ។ ប្រទេសទាំងនេះបានបន្តការពង្រឹងសកម្មភាពរបស់ពួកគេ ដោយអនុវត្តវិធានការដូចមានចែងក្នុងផែនការសកម្មភាព ។ ពត៌មានស្តីពីការបន្ថយការរាលដាលនៃការជក់ ពារីមិនទាន់មានច្បាស់នៅឡើយចំពោះប្រទេសទាំងនេះ ។

*២.ប្រទេសដែលមិនទាន់ធ្វើសកម្មភាពមុនឆ្នាំ ១៩៩០*

ប្រទេស៨ក្នុងចំណោមប្រទេសទាំង១៣មិនទាន់ បានធ្វើសកម្មភាពណាមួយមុនឆ្នាំ ១៩៩០ តែនៅពេលនោះបានបង្កើតសកម្មភាពជាតិហើយ ។ ប្រទេសទាំងនោះគឺ ហ្វីជី ឡាវ កោះម៉ារីយ៉ាណាខាងជើង ហ្វីលីពីន កោះសូឡូម៉ុង តុងហ្គា

វៀណ្ណូទូ និងវៀតណាម ។

*៣.ការលើកឡើងនៃសកម្មភាពនៅប្រទេសនានៅអាស៊ីប៉ាស៊ីភិច*

- អូស្ត្រាលី : ការព្រមានដោះពុម្ពថ្មីៗ រួមមាន"ការជក់ប្រហាជីវិត" នៅផ្នែកខាងលើនៃកញ្ចប់ និង ៣០% នៃផ្នែកខាងក្រោយនៃកញ្ចប់ ។ ការអនុវត្តច្បាប់ហាមមិនអោយផ្សាយពាណិជ្ជកម្ម និងការឧបត្ថម្ភនានា ។
- ចិន : ការអនុវត្តច្បាប់គ្រប់គ្រងថ្នាំជក់សំខាន់ៗនិងការធ្វើអង្កេតមួយស្តីពីផ្នែខាតបង់ខាងសេដ្ឋកិច្ចនៃថ្នាំជក់ ។
- ហ្វីជី : ការបង្កើតក្រុមប្រឹក្សាប្រឆាំងថ្នាំជក់ជាតិ (NSSSF) ។
- ហុងកុង : បង្កើតច្បាប់ប្រចាំឆ្នាំ ។
- ឡាវ : ការប្រារព្ធទិវាពិភពលោកគ្មានថ្នាំជក់លើកទី១ នៅឆ្នាំ១៩៩៣ ការដាក់កំហិតលើការផ្សាយពាណិជ្ជកម្ម ខ្លះៗ និងសារាចរហាមប្រាមការជក់នៅទីកន្លែងសាធារណៈ ។
- ជប៉ុន : ការផ្សាយនៅឆ្នាំ ១៩៩៣ ដោយក្រសួងសុខាភិបាលនៃការបោះផ្សាយលើកទី២ សៀវភៅទំព័រស (White Paper)របាយការណ៍នៃការជក់ និងសុខភាព និងសៀវភៅណែនាំស្តីពីថ្នាំជក់ ឬសុខភាពសំរាប់អ្នកមាន អាជីពផ្នែក សុខាភិបាល ។
- ម៉ាឡេស៊ី : ការអនុវត្តច្បាប់ ។
- ញូស៊ីលែន : ឆ្នាំ ១៩៩០ បរិស្ថានគ្មានផ្សែងជក់ ការឧបត្ថម្ភកម្មវិធីវប្បធម៌ និង កីឡាជាង ៥៥០ កម្មវិធីចន្លោះឆ្នាំ ១៩៩១-១៩៩៣ ដោយក្រុមប្រឹក្សាឧបត្ថម្ភផ្នែកសុខភាព ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៩០ ។
- ហ្វីលីពីន : កម្មវិធីរៀបចំដោយសហគមន៍ រួមមានការបង្កើតរូបត្ថក ។
- សិង្ហបុរី : ការអប់រំបន្ត វិធានការច្បាប់ និងការទទួលស្គាល់តំរូវការដើម្បីត្រួតពិនិត្យ និងបន្តការប្រឹងប្រែង ។
- វៀតណាម : ការហាមឃាត់ទាំងស្រុងស្តីពីការផ្សាយពាណិជ្ជកម្មថ្នាំជក់ ។

## ២.៣_ការបូកសរុបផែនការសកម្មភាពស្តីពីថ្នាំជក់ ឬសុខភាពសំរាប់ឆ្នាំ ១៩៩៥_១៩៩៩

ផែនការសកម្មភាពស្តីពីថ្នាំជក់ ឬសុខភាពសំរាប់ឆ្នាំ ១៩៩៥-១៩៩៩ អំពាវនាវដល់រដ្ឋាភិបាលទាំងអស់អោយ អនុវត្តវិធានការត្រួតពិនិត្យថ្នាំជក់នៅឆ្នាំ ១៩៩៩ ។ វិធានការណ៍ទាំងនេះរួមមាន គោលនយោបាយជាតិមួយ និងទីភ្នាក់ងារ សំរបសំរួលកណ្តាលមួយស្តីពីថ្នាំជក់ឬសុខភាព ការអប់រំសុខភាព ច្បាប់ត្រួតពិនិត្យថ្នាំជក់ និងគោលនយោបាយថ្លៃ ។

# ៣_សភាពការណ៍ថ្នាំជក់នៅកម្ពុជា

## ៣.១ ការប្រើប្រាស់ថ្នាំជក់នៅកម្ពុជា

នៅកម្ពុជា បារីត្រូវបានគេផ្តល់ជាលក្ខណៈប្រពៃណីយ៍ប្រគេនព្រះសង្ឃដើម្បីធ្វើបុណ្យ និងប្រគេនទ័យទានក្នុងពិធីផ្សេងៗ ។ វាបានក្លាយជាប្រពៃណីយ៍ដ៏សំខាន់ដែរនៅក្នុងពិធីមង្គលការដែលគូរស្វាមី ភរិយាថ្មីៗតែងតែចែកចាយបារីជូន ដល់ភ្ញៀវដើម្បីជក់ក្រោយពេលបញ្ចប់ពិធីលាងសាយភោជន៍ ។ លើសពីការជក់បារី ថ្នាំជក់ក៏ត្រូវបានគេប្រើជាបារីមូរដៃក៏ដូច ជាចំណុកថ្នាំសំរាប់មុស្សចាស់ៗ នៅកម្ពុជា (ពិសេសគឺយាយៗ) ។

មានបារីប្រហែលជា ២២៣ ម៉ាកកំពុងដាក់លក់នៅកម្ពុជា ។ ក្នុងនោះបារី 555 , MARLBORO, និង MILD SEVEN គឺជាបារីដែលលក់ដាច់ជាងគេ ។ គេប៉ាន់ស្មានថា ៣០ ៖ នៃការនាំចូលគឺជាបារី ។

ថ្នាំជក់ត្រូវបានគេដាំនៅក្នុងខេត្ត ៤ គឺ : កំពង់ចាម កណ្តាល ព្រៃវែង និងក្រចេះ ។ នៅឆ្នាំ ១៩៩០ គេផលិតសន្លឹកថ្នាំជក់ ៥.៩៦០តោន ឬប្រហែលជា ០,១ ៖ នៃផលិតផលសរុបនៃពិភពលោកដែលកើនឡើងពី ៤.៩៨១តោន នៅឆ្នាំ ១៩៨០ ។ នៅឆ្នាំ ១៩៩២ កម្ពុជាបានផលិតបារីប្រហែលជា ៦.៨២០លានដើម[5] ។

របាយការណ៍មួយរបស់ទីប្រឹក្សា WHO បានគូសបញ្ជាក់ថា ការប្រើប្រាស់ថ្នាំជក់នៅឆ្នាំ ១៩៩៥ មាន ៧ពាន់លាន ដើម (ឬ ៥.៩៥០តោន ដោយគណនា១.០០០ដើមស្មើនឹង ០.៨៥គក្រ)រួមទាំងបារីក្នុងស្រុក ។

នៅឆ្នាំ ១៩៩៦ ផ្អែកលើរបាយការណ៍ដែលគណនាដោយទីស្នាក់ការគយគេឃើញថាមានសន្លឹកថ្នាំជក់ ១.២៨៨តោន និងបារី ៤.៥០០តោន បាននាំចូលមកកម្ពុជា និងបានជាប់ពន្ធ ។

ការប៉ាន់ស្មាននៃការប្រើប្រាស់ថ្នាំជក់នៅកម្ពុជានៅឆ្នាំ ១៩៩៥ គឺ ៧ពាន់លានដើម ឬ ៥.៩៥០តោន ។ តួលេខនេះអាចប៉ាន់ស្មានទាបប្រសិនបើយើងប្រៀបធៀបនឹងតួលេខឆ្នាំ ១៩៩៦ ដែលមានសន្លឹកថ្នាំជក់ ១.២៨៨ តោន និងបារី ៤.៣៣៤តោន (សរុប ៥.៨២២តោន) ។ ប្រសិនបើយើងបន្ថែមផលិតផលថ្នាំជក់ក្នុងស្រុក ដូច រៀបរាប់ខាងលើ ៥.៩៦០តោន ក្នុងឆ្នាំ ១៩៩០ យើងនឹងទទួលបានតួលេខកាន់តែខ្ពស់ ។

នៅឆ្នាំ ១៩៩៧ គេប៉ាន់ស្មានថាយ៉ាងហោចណាស់មានបារី ៧,៦ពាន់ លានដើម ត្រូវបានគេប្រើប្រាស់នៅកម្ពុជា ។ គ្រាន់តែ លើកឡើងពី BAT (ក្រុមហ៊ុនថ្នាំជក់អង់គ្លេស,អាមេរិក)ប៉ុណ្ណោះ គេផលិតបារីជាង ២ពាន់លានដើមក្នុងមួយឆ្នាំ ។ តួលេខនេះនឹងកើនឡើង ដោយក្រុមហ៊ុននេះមានផែនការពង្រីកទីផ្សារ និងផលិតកម្ម ។

## ៣.២ សកម្មភាពជំរុញថ្នាំជក់

ឧស្សាហកម្មថ្នាំជក់ពហុជាតិ មានវត្តមានយ៉ាងធំនៅកម្ពុជា ។ មកទល់ពេលនេះពួកគេបានបណ្តាក់ទុន នៅរោងចក្រ ថ្នាំជក់ចំនួន ១២ នៅកម្ពុជាតាមរយៈបណ្តាញលើកទឹកចិត្តក្នុងច្បាប់វិនិយោគដែលត្រូវបានគេចាត់ទុក ជាច្បាប់វិនិយោគសេរី និង អនុគ្រោះបំផុតនៅក្នុងតំបន់ ។ ការវិនិយោគក្នុងឧស្សាហកម្មថ្នាំជក់គឺភាគច្រើនមកពីអង់គ្លេស បារាំង ចិន សាំងហ្គាពួរ និងអ្នកវិនិយោគ ក្នុងស្រុក ។ ក្រុមហ៊ុនវិនិយោគអន្តរជាតិ អង់គ្លេស-អាមេរិក (BAT) និងក្រុមហ៊ុនបារាំងមួយ បានបើក ទុនចំរុះក្នុងការ ផលិតបារីនៅនៅទីនេះ ។

សកម្មភាពជំរុញថ្នាំជក់នៅកម្ពុជាមានការប្រណាំងប្រជែងណាស់ ហើយវាត្រូវបានគេជួបប្រទះនៅគ្រប់ កន្លែងក្នុងទីក្រុង និងភូមិដាច់ស្រយាល ។ មានការផ្សាយពាណិជ្ជកម្មតាមផ្លូវប្រហែលជា ៣៦ ៖ គឺជាការផ្សាយបារី ។ ការផ្សាយ ពាណិជ្ជកម្មបារីបានកើនឡើង ៤០០៖ ក្នុងភ្នំពេញតាំងពីឆ្នាំ១៩៩៦មក[2] ។ ការផ្សាយពាណិជ្ជកម្មមានភាពសកម្មណាស់ ។ វាត្រូវបានគេធ្វើដោយគ្មានការដាក់កំហិតមិនត្រឹមតែតាមរយៈ ទូរទស្សន៍ វិទ្យុ ទស្សនាវដ្តី ឬសារពត៌មានឡើយ តែវាក៏ត្រូវបាន ជំរុញតាមរយៈការចែកចាយបារី ។ នារីស្អាតៗត្រូវបានគេចាត់តាំងអោយដើរចែកចាយ បារីដោយឥតគិតថ្លៃតាមផ្លូវ ក្នុង ភោជនីយដ្ឋាន រង្គសាល និងតាមទីកន្លែងដទៃទៀត ។ មិនតែប៉ុណ្ណោះក៏មានការឧបត្ថម្ភដោយក្រុមហ៊ុន បារីជាច្រើន ដល់សកម្មភាពកីឡា និងពិធី បុណ្យទានា ។

តាមរយៈអង្កេតមួយដែលធ្វើឡើងដោយអង្គការ ADRA និងក្រសួងសុខាភិបាលនៅខែតុលា ១៩៩៤ គេដឹងថា យ៉ាងហោចណាស់៦៥%នៃបុរសនៅតំបន់ទីក្រុង និង៨៦% នៃបុរសនៅតំបន់ជនបទដែលបានធ្វើអង្កេត គឺជាអ្នកជក់ថ្នាំ ។ អត្រានេះត្រូវបានគេចាត់ទុកថាជាការរាលដាលមួយដ៏ខ្ពស់ក្នុងចំណោមប្រជាជនកម្ពុជា ។ វាប្រហែលជាអាចមានការកើនឡើងនៃចំនួនស្ត្រីជក់ថ្នាំដែរ តែគ្មានទិន្នន័យច្បាស់លាស់[1] ។

ក្រសួងសុខាភិបាលមិនទាន់មានឥទ្ធិពលគ្រប់គ្រាន់ ដើម្បីបញ្ឈប់ការផ្សាយពាណិជ្ជកម្មថ្នាំជក់ទេដោយ សារមជ្ឈដ្ឋានពត៌មានត្រូវការលុយពីកម្មវិធីបែបនេះដើម្បីគាំទ្រសកម្មភាពពាណិជ្ជកម្មរបស់គេ ។

## ៤_ច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាលដើម្បីគ្រប់គ្រងថ្នាំជក់

មកដល់ពេលនេះគ្មានការដាក់កំហិតដល់ការផលិត និងការនាំចូលថ្នាំជក់នៅកម្ពុជាឡើយ ។ ថ្នាំជក់ត្រូវបានគេចាត់ទុកជាទំនិញដ៏សំខាន់មួយដែលផ្តល់ផ្នែកដ៏ធំមួយនៃចំណូលជាតិ (ប្រហែល១៨%នៃចំណូលសរុប) ។ ដោយហេតុនេះហើយ ក្នុងសភាពការណ៏បច្ចុប្បន្នវាជាការលំបាកណាស់ ដើម្បីទប់ស្កាត់ឬដាក់របាំងទាំងផ្នែកពន្ធដារ ឬមិនមែនពន្ធដារលើការ ផលិតនិងនាំចូលថ្នាំជក់ ។ យុទ្ធនាការជាតិមួយហៅថា “ទិវាពិភពលោកគ្មានថ្នាំជក់” ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ តាំងពីឆ្នាំ ១៩៩៣ ។ ទិវានេះត្រូវបានរៀបចំឡើងដោយក្រសួងសុខាភិបាល ដោយមានការឧបត្ថម្ភពីសំណាក់អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន ដែលពេលនោះ ផ្ទាំងស្និត បដា រូបភាព អាវយឺត និងខិតប័ណ្ណត្រូវបានគេចែកចាយ ។ សកម្មភាពដទៃ ទៀតដូចជាការសំដែងជន្ត្រី ចំរៀង ការប្រកួតប្រជែងរូបភាពប្រឆាំងការជក់បារី និងសិក្ខាសាលាចំនួន៣ស្តីពីគោលយោបាយ គ្រប់គ្រងថ្នាំជក់ត្រូវបាន ធ្វើតាំងពីឆ្នាំ ១៩៩៥ ។

ក្រសួងសុខាភិបាលបានអនុម័តការទប់ស្កាត់ចំពោះការផ្សាយពាណិជ្ជកម្មបារីតាមទូរទស្សន៍ និងវិទ្យុប៉ុន្តែគេមិនបានអនុវត្តទេ ។ ក្រសួងអាចបន្ថែមការប្រមានជាអក្សរខ្លីមួយ “ពិសារបារីនាំអោយខូចសុខភាព” ដែលតាមធម្មតារហ័ស និងអានមិនទាន់ ។

## ៤.១ សកម្មភាពត្រួតពិនិត្យការជក់ បារី

នៅឆ្នាំ ១៩៩៣ មានការហាមប្រាមមិនអោយផ្សាយពាណិជ្ជកម្មលើ មជ្ឈដ្ឋានផ្សាយពត៌មានសាធារណៈ ។ តែវាមិនទាន់ទាក់ទងដល់មជ្ឈដ្ឋានផ្សាយឯកជនឡើយ ។ ការហាមប្រាមបែបនោះនាំអោយមាន ការផ្សាយពាណិជ្ជកម្មតាមបែបផ្សេងទៀតដូចជា ការតាំងយីហោ ការបោះពុម្ពជាដើម ។ ការផ្សាយពាណិជ្ជកម្ម ប្រយោលក៏កើតមានលើផលិតផលដូចជា អាវយឺត អំត្រ ដែកកេះ ប៊ិច និងថង់កីឡា ។ គ្មានការព្រមាន សុខភាពលើផលិតផលថ្នាំជក់ទេ ។

នៅឆ្នាំ ១៩៩៤ ទីស្តីការគណៈរដ្ឋមន្ត្រីបានប្រគល់សិទ្ធអោយក្រសួងសុខាភិបាលអនុវត្តការអប់រំសុខភាព ទប់ស្កាត់ការជក់នៅគ្រប់ការិយាល័យរដ្ឋាភិបាល ទីសាធារណៈ និងមធ្យោបាយដឹកជញ្ជូនជាដើម ។

នៅឆ្នាំ ១៩៩៦ ក្រសួងសុខាភិបាលបានសរសេរលិខិតមួយដើម្បីស្នើ និងជូនយោបល់ដល់ :

១.ក្រសួងពត៌មានអោយដាក់ការព្រមានសុខភាពលើគ្រប់ការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ វិទ្យុ សារពត៌មានទស្សនាវដ្តី ។ (ការព្រមានសុខភាពខ្លីមួយត្រូវបានដាក់នៅចុងការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍) ។

២.ក្រសួងការពារប្រទេសឱ្យដាក់ការព្រមាន លើការផ្សាយនៃស្ថានីយ៍ទូរទស្សន៍របស់ខ្លួន (ក្រសួងការពារប្រទេសមានស្ថានីយ៍ ទូរទស្សន៍មួយ) ។

៣.ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ដាក់ការព្រមានមួយលើកញ្ចប់ បារី (តែគ្មានការឆ្លើយតប) ។

៤.ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យពិចារណាការតំឡើងពន្ធលើបារី ។

៥.ក្រសួងពាណិជ្ជកម្មឱ្យបិទផ្លាកព្រមានលើបារីនាំចូល ។

៦.អភិបាលក្រុងភ្នំពេញឱ្យដាក់ផ្លាកព្រមានមួយក្នុងប៉ាណូផ្សាយបារីទាំងអស់ ។

៧.បុគ្គលិកនៃគ្រប់ស្ថាប័នទាំងអស់ក្រោមក្រសួងសុខាភិបាល មិនឱ្យជក់ក្នុងកន្លែងធ្វើការ ។ (ប្រហែល ជា៩៥% បាន អនុវត្តតាមការណែនាំនេះ មន្ទីរពេទ្យធំៗនៅទីក្រុងភ្នំពេញ បានហាមប្រាមការជក់បារី តែមានមន្ទីរពេទ្យខេត្ត ជាច្រើន មានវេជ្ជបណ្ឌិតជក់ជាចំហរ ។

នៅឆ្នាំ ១៩៩៥ ក្នុងជើងហោះហើរអន្តរជាតិ និងក្នុងស្រុករបស់អាកាសចរណ៍ភូមិន្ទកម្ពុជា ការជក់បារី ត្រូវបានហាមឃាត់ទាំងស្រុង ។

នៅឆ្នាំ ១៩៩៧ អាកាសយានដ្ឋានពោធិចិនតុងជាកន្លែងមិនជក់ បារីតែអនុញ្ញាតិឱ្យមានបន្ទប់ជក់មួយ ។

មានស្ថានីយ៍សំបុកឃ្មុំ១០៥មេហ្គាហឺត មិនទទួលយកការផ្សាយពាណិជ្ជកម្មថ្នាំជក់ទេ ហើយស្ថានីយ៍នោះ ជារឿយៗផ្តល់ ការអប់រំល្អៗ ស្តីពីផលប៉ះពាល់សុខភាពរបស់ថ្នាំជក់ ។

## ៤.២ រចនាសម្ព័ន្ធពន្ធដារ

នៅឆ្នាំ ១៩៩៤ រដ្ឋាភិបាលសំរេចថា ខ្លួនមិនអាចបញ្ឈប់ការរត់ពន្ធបារីបានទេ ។ មានការត្រួតពិនិត្យខ្លះ លើការនាំចូល តែគ្មានការត្រួតពិនិត្យលើការនាំចេញទេ ។ ដូច្នេះរដ្ឋាភិបាលបានសំរេចរៀបចំពន្ធដារឱ្យទាបបន្តិចសំរាប់បារីរត់ពន្ធ ជាងបារី ដែលនាំចូលសំរាប់ការប្រើប្រាស់ក្នុងស្រុក ។ គ្មានអត្តសញ្ញាណណាមួយដែលគេអាចសំគាល់ថា បារីនាំចូលណាសំរាប់ ប្រើប្រាស់ក្នុងស្រុក និងបារីណាជាបារីសំចតសំរាប់នាំចេញបន្តឡើយ ។ ក្រុមហ៊ុននាំចូលបារីបានបង់ពន្ធក្នុងស្រុកខ្ពស់លើបារី ២០ % និងពន្ធទាបលើ ៨០ % នៃបារីនាំចូល ។

ពន្ធគយនាំចូលសំរាប់សន្លឹកថ្នាំជក់ដែលជាវត្ថុធាតុដើមគឺ១៥%នៃតំលៃសរុប និងពន្ធគយលើបារីគឺ ៥០% នៃតំលៃសរុប ។

ពន្ធនានាដែលត្រូវបង់លើបារីសំរាប់ការប្រើប្រាស់ក្នុងស្រុក

| | |
|---|---|
| ពន្ធគយ | ៥០ % |
| ពន្ធប្រើប្រាស់ | ១០ % |
| ពន្ធលើផលរបរ | ៤ % |
| ថ្លៃបង់ដទៃទៀត | ៧.៦ % |
| <u>សរុប</u> | ៧១.៦ % |

ពន្ធនានាដែលត្រូវបង់លើបារីសំរាប់នាំចេញបន្ត (គ្មានពន្ធប្រើប្រាស់ទេ)

| | |
|---|---|
| ពន្ធគយ | ៥០ % |
| ពន្ធលើផលរបរ | ៤ % |
| ថ្លៃបង់ដទៃទៀត | ៧.៦ % |
| <u>សរុប</u> | ៦១.៦ % |

## ៥.ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃថ្នាំជក់ក្នុងកម្ពុជា

### ៥.១ អំណះអំណាងផ្សេងៗគ្នា

ក្រុមហ៊ុនថ្នាំជក់តែងតែបានត្រៀមខ្លួនជាស្រេចក្នុងការតវ៉ាប្រឆាំងនឹងការរឹតត្បិតបារី ។

ថ្នាំជក់មានសារសំខាន់ណាស់ខាងសេដ្ឋកិច្ច គេតវ៉ាពីព្រោះ :

- ថ្នាំជក់ផលិតចំណូលផ្នែកពន្ធដារ
- ការនាំចេញថ្នាំជក់ នាំមករូបិយប័ណ្ណខ្លាំង
- ថ្នាំជក់បង្កើតការងារ
- ថ្នាំជក់ជាដំណាំដ៏សំខាន់

គេតវ៉ាថា សកម្មភាពបន្ថយការជក់ថ្នាំនឹងនាំមកនូវការខូចខាតដល់សេដ្ឋកិច្ច បាត់បង់ការងារ បាត់បង់ចំណូល ពន្ធនឹងធ្លាក់ចុះ ការនាំចេញនឹងធ្លាក់ចុះ កសិករនឹងនឹងខាតបង់ ។ ប៉ុន្តែគេមិនដែលលើកឡើង ពីការខាតបង់ខាងសេដ្ឋកិច្ច ដែលថ្នាំជក់បង្ក ដល់គ្រប់ប្រទេសទេ ។

ផលិតផលថ្នាំជក់អាចជាប្រភពចំណូលមួយរបស់រដ្ឋាភិបាលហើយអាចបង្កើតការងារ ។ ប៉ុន្តែមានតំលៃ ដែលអាចរាប់បាន និងមិនអាចរាប់ បានចំពោះសេដ្ឋកិច្ចនិងសង្គម ។ ថ្នាំជក់ដែលធ្វើពាណិជ្ជកម្មនៅទីផ្សារបាន បន្ថែមតំលៃខាតបង់មួយទៅលើសុខមាលភាពពិភពលោក ។ វាជាការពិត វាក៏អាចមានការរីករាយរបស់អ្នក ប្រើប្រាស់ និងផលចំណេញរបស់អ្នកផលិត ប៉ុន្តែចំណេញអស់នេះត្រូវបានសងដោយការខូចខាតដោយពិការភាព និងមរណភាពដែលបង្កដោយថ្នាំជក់ ។

ការប្រើប្រាស់ថ្នាំជក់ជះឥទ្ធិពលដល់សេដ្ឋកិច្ចនិងសុខភាពផងដែរ ។ ការសិក្សាស្រាវជ្រាវស្តីពីផល ប៉ះពាល់ថ្នាំជក់ជាច្រើនត្រូវបានគេធ្វើនៅប្រទេសខ្លះៗក្នុងតំបន់ ។ នៅពេលដែលរដ្ឋាភិបាលអាចទាញបានផល ចំណេញរយៈពេលខ្លីពីពន្ធដារនៃថ្នាំជក់ ថ្នាំជក់តែងតែបង្កើតការបង់ខាតសដល់សេដ្ឋកិច្ចក្នុងប្រទេស ។ តំលៃខាតបង់នោះរួមមាន :

- ថ្លៃព្យាបាលខាងវេជ្ជសាស្ត្រ និងសុវត្ថភាពកើនខ្ពស់
- បាត់បង់ផលិតភាព
- អគ្គីភ័យបង្កដោយការជក់ធ្វេសប្រហែស
- ការនាំចូលនិងការទិញបារីបរទេស ការទិញសម្ភារៈបរិក្ខាសំរាប់រោងចក្របារី ការជួលបុគ្គលិកបរទេស ។
- ការកាប់ព្រៃឈើបណ្តាលពីការប្រើប្រាស់ដើម្បីថ្នាំជក់
- ការប្រើប្រាស់ដីខុសទិសដៅលើការដាំថ្នាំជក់ជំនួសឱ្យដំណាំអាហារ (ឧទាហរណ៍ : នៅប្រទេសចិន ១,២ ៖ នៃដីដែលអាចដាំដុះបានគេប្រើសំរាប់ថ្នាំជក់)
- បន្ថយអាយុកាល

### ៥.២ ជម្ងឺ និងមរណភាពដែលបង្កដោយការប្រើប្រាស់ថ្នាំជក់ ១.០០០គោរន

ជាសកល ថ្នាំជក់បានបង្កឱ្យមនុស្សស្លាប់ ៣លាននាក់កាលពីឆ្នាំមុន ហើយគេរំពឹងថា នឹងបណ្តាលឱ្យ មានមនុស្សស្លាប់ដល់ទៅ ១០លាននាក់នៅឆ្នាំ ២០២៥ ។ ក្នុងចំណោមអ្នកស្លាប់ ៨នាក់ ក្នុងនោះអ្នកស្លាប់ ១នាក់ បណ្តាលមក

ពីថ្នាំជក់ នៅក្នុងប្រទេសក្រីក្រ ហើយអ្នកស្លាប់ ១នាក់ក្នុងចំណោមអ្នកស្លាប់ ៤នាក់ ក្នុងប្រទេសអភិវឌ្ឍន៍ និងមានអ្នកស្លាប់ ១នាក់ក្នុងចំណោមអ្នកស្លាប់ ៦នាក្នុងពិភពលោក បើនិយាយជារួម ត្រូវស្លាប់បណ្តាលមកពីថ្នាំជក់(13)។

ដើម្បីប៉ាន់ស្មានពីផលប៉ះពាល់សេដ្ឋកិច្ចបង្កមកពីជម្ងឺ និងមរណភាពដែលទាក់ទងនឹងថ្នាំជក់ លោក BARNUM បានប៉ាន់ស្មានឥទ្ធិពលនៃការប្រើប្រាស់ថ្នាំជក់ ១.០០០តោន ។ ក្នុងអត្ថបទមួយដែលត្រៀមសំរាប់ ធនាគារពិភពលោក ដើម្បីជាគំនិតដល់គោលនយោបាយធនាគារពិភពលោក កុំឱ្យការផ្តល់ខ្ចីបុលសំរាប់អាជីវកម្មថ្នាំជក់ គាត់បានប៉ាន់ស្មានពីផលចំណេញរបស់អ្នកផលិត និងអ្នកប្រើប្រាស់ថ្នាំជក់ប្រៀបធៀបជាមួយតំលៃខាតបង់ ខាងសេដ្ឋកិច្ច(6) ។

*តារាងទី ២ : ជម្ងឺ និងមរណភាពពីការប្រើប្រាស់ ១.០០០តោនថ្នាំជក់*

| ជម្ងឺ | ករណីថ្មីប្រចាំឆ្នាំ | ករណីស្លាប់ប្រចាំឆ្នាំ |
|---|---|---|
| Cancer | 230 | 200 |
| Cardiovascular | 440 | 330 |
| Cerebrovascular | 130 | 50 |
| COPD | 190 | 70 |
| Total | 990 | 650 |

*Estimated From US data; COPD= Chronic Obstructive Pulmonary Disease*

*តារាងទី ៣ : ថ្លៃខាតបង់ និងផលចំណេញពីការប្រើប្រាស់ ១.០០០តោនថ្នាំជក់*

| ឥទ្ធិពល | ផលចំណេញ | ថ្លៃខាតបង់ | តុល្យភាព |
|---|---|---|---|
| Consumer & Producer benefits | 2.6 | | 2.6 |
| Premature Death | | 13.2 | -13.2 |
| Indirect morbidity costs | | 11.0 | -11.0 |
| Direct morbidity costs | | 5.6 | -5.6 |
| ***Total*** | **2.6** | **29.8** | **-27.2** |

នៅកម្ពុជា ការចំណេញសំរាប់ថ្នាំជក់ បានគ្របដណ្តប់មួយផ្នែកដ៏ធំនៃចំណាយក្នុងគ្រួសារ បន្ថែមលើការចំណាយលើស្បៀងអាហារ ការអប់រំ និងសុខាភិបាល ។ អាស្រ័យទៅតាមការធ្វើអង្កេតរបស់អង្គការADRA គេប៉ាន់ស្មានថា ទៅតាមផលប៉ះពាល់លើសុខភាព និងសេដ្ឋកិច្ច ការជក់បារីក៏មានផលប៉ះពាល់យ៉ាងខ្លាំងដល់គ្រួសារ ។ គេប៉ាន់ស្មានថា នៅតំបន់ទីក្រុងគេចំណាយ ១៧៖ និងនៅជនបទគេចំណាយ ៨៖ ទៅលើបារី ។ ប៉ុន្តែគេបែរជាទទួលការបង់ខាតច្រើនជាងការចំណាយ ។

ការអង្កេតមួយដែលត្រូវបានធ្វើឡើងដោយវេជ្ជបណ្ឌិត ឃួន វិចិត្រ ទៅលើករណីមហារីកចំនួន ២៧២នាក់ នៅតាមផ្នែកទាំងបីនៃមន្ទីរកាលម៉ែត្រនៅឆ្នាំ ១៩៩៥-១៩៩៦បានរកឃើញថា មានករណីមហារីកសួតចំនួន ២៧ករណី ឬ ៩,២៧៖ ។ ប្រហែលជា ៥០៖នៃករណីទាំងអស់បានជះឥទ្ធិពលទៅលើក្រុម មនុស្សដែលមានអាយុពី ៣៥ទៅ ៨៦ឆ្នាំ ។ ក្នុងនោះការរាលដាលគ្របដណ្តប់លើបុរសប្រមាណ ៨៥,៧៖ និងលើកសិករប្រមាណ ៥៧៖ ។ ការសិក្សានោះគ្រាន់តែធ្វើលើគំរូអង្កេតតូចមួយ តែវាអាចផ្តល់ទិន្នន័យជាមូលដ្ឋានបញ្ជាក់ពីការកើនឡើងនៃគ្រោះថ្នាក់ដែលបង្កឡើងដោយថ្នាំជក់ ។

## ៥.៣ តំលៃខាតបង់

តំលៃខាតបង់ខាងសេដ្ឋកិច្ច សំដៅលើការខាតបង់ផ្ទាល់ និងប្រយោល ។ តំលៃផ្ទាល់រួមមាន ការចំណាយលើការថែទាំសុខភាព ការព្យាបាល និងការពារដោយបុគ្គលរដ្ឋ និងអង្គការនានាលើជម្ងឺដែលបណ្តាល ដោយថ្នាំជក់ ។ តំលៃប្រយោលសំដៅលើថ្លៃខាតបង់ខាងផលិតកម្មអាស្រ័យដោយពិការភាព និងការស្លាប់មុនអាយុ ។

ក្នុងការសិក្សានេះ មានតែតំលៃខាតបង់ប្រយោលទេដែលត្រូវបានគណនាដោសារមានការខ្វះខាតខាងទិន្នន័យ ។

### ការវាលដាលនៃករណីស្លាប់

*ក/.ការប៉ាន់ស្មានករណីស្លាប់ដោយផ្អែកលើអត្រាគ្រោះថ្នាក់នៃពិភពលោក*

ដោយផ្អែកលើអត្រាមរណៈនៃពិភពលោកដែលត្រូវបានគេប៉ាន់ស្មានថា មានមនុស្សស្លាប់ ៣លាននាក់ រៀងរាល់ឆ្នាំ ដោយសារថ្នាំជក់ ។ ក្នុងចំណោមប្រជាជន ៥,៨ពាន់លាននាក់ក្នុងពិភពលោក យើងអាចរកឃើញថា អត្រាស្លាប់មាន ០,០៥៥៖ ។ ដោយប្រើប្រាស់អត្រានេះ នៅប្រទេសកម្ពុជាដែលមានប្រជាជន ១០,៧ លាននាក់ អាចមានមនុស្សស្លាប់ ៥.៨៨០នាក់ រៀងរាល់ឆ្នាំដោយការប្រើប្រាស់ថ្នាំជក់ ។ ការប៉ាន់ស្មាននេះ មានកំរិតទាបជាងការពិតដោយការប្រើប្រាស់ថ្នាំជក់នៅអាស៊ីមានសន្ទុះ ខ្ពស់ជាងតំបន់ដទៃទៀតនៃពិភពលោក ។

*ខ/.ការប៉ាន់ស្មានដោយផ្អែកលើការប្រើប្រាស់ថ្នាំជក់នៅកម្ពុជា*

ការប៉ាន់ស្មានមួយទៀតត្រូវបានគណនាដោយផ្អែកលើការប្រើប្រាស់ថ្នាំជក់នៅកម្ពុជា ។ ដោយប្រើប្រាស់ ទិន្នន័យនៃការស្រាវជ្រាវដែលប៉ាន់ស្មានដោយទិន្នន័យសហរដ្ឋអាមេរិក US data គេដឹងថា ការប្រើប្រាស់ ១.០០០តោន នៃថ្នាំជក់នឹងបង្កឱ្យមានមនុស្សស្លាប់៦៥០នាក់ ។ ដោយសារការប្រើប្រាស់បារីនៅកម្ពុជាមាន ប្រហែល ៧.៦០០លានដើម (ឬ ៨.៩៤១តោន) ។ ដូច្នេះអាចមានមនុស្សស្លាប់ ៥.៨១១នាក់ដោសារថ្នាំជក់រៀងរាល់ឆ្នាំ ។

ការប៉ាន់ស្មានទាំងពីរខាងលើ ទទួលបានលទ្ធផលប្រហែលគ្នា ។ អាស្រ័យហេតុនេះតួលេខករណីស្លាប់ ប្រហែល ៥.៨០០នាក់ អាចទទួលយកបាន ។

## ៥.៤ ផលចំណេញ

តាមប្រភពពីទីស្នាក់ការគយបានឱ្យដឹងថា ចំណូលពន្ធដែលប្រមូលបានពីថ្នាំជក់នាំចូលដល់ទៅ ៤លាន- ដុល្លា ចំពោះបារីដែលនឹងនាំចេញបន្ត និង ៥លានដុល្លាក្នុង១ត្រីមាសនៃឆ្នាំ១៩៩៥ សំរាប់ប្រើប្រាស់ក្នុងស្រុក ។ ចំណែកពន្ធលើបារីផលិតក្នុងស្រុកក៏ទទួលបានចំណូល ក៏ចំណូលគួរជាទីពេញចិត្តដែរ ។ ប្រហែលជា ៤៨៖នៃតំលៃបារីគឺជាពន្ធគិតជាតំលៃ ប្រហែល ១៦លានដុល្លាក្នុងមួយឆ្នាំ ។ ដោយហេតុនេះ ចំណូលពន្ធសរុបដែលទទួលបានពីបារីនៅឆ្នាំ ១៩៩៥ មានរហូតដល់ ៥២លានដុល្លា (ឬ ១,៨៖នៃ GDP ឬ ១៨៖នៃចំណូលសរុប)ដែលជាប្រភពចំណូលមួយធំបំផុតក្នុងថវិកាជាតិ ។

## ៥.៥ ការប៉ាន់ស្មានតំលៃខាតបង់ និងផលចំណេញផ្សេងៗគ្នា

ការប៉ាន់ស្មាននៃអត្រាស្លាប់ តំលៃខាតបង់ដោយប្រយោល និងផលចំណេញនៃថ្នាំជក់នៅកម្ពុជា ត្រូវបានធ្វើក្នុង ទិដ្ឋភាព (Scenario) បីផ្សេងៗគ្នា ដោយប្រើប្រាស់តួលេខខាងលើ និងការសន្មតដូចខាងក្រោម ។

-អត្រាកំណើននៃអ្នកជក់ និងចំណូលពន្ធពីថ្នាំជក់គឺផ្អែកលើកំណើនរបស់ប្រជាជន ២,៨៖/១ឆ្នាំ ។

-ការគណនាតម្លៃខាតបង់ ប្រយោលត្រូវបានធ្វើដោយផ្អែកលើផលិតផលសង្គមសរុបក្នុងមនុស្សម្នាក់ៗ (GDP) តាមការប្រៀបធៀបតម្លៃ (Purchasing Power Parity) ។

-ការបាត់បង់ក្នុងមនុស្សស្លាប់ម្នាក់ដោយថ្នាំជក់ ត្រូវបានប៉ាន់ស្មានថាអស់ពេល ១៥ឆ្នាំការងារ ។ ការប៉ាន់ស្មាននេះមានកំរិតទាបនៅឡើយ បើយើងប្រៀបធៀបទៅនឹងការបាត់បង់ដោយមនុស្សស្លាប់ពីជម្ងឺអេដស៍ (4)។

-ការប៉ាន់ស្មាន ត្រូវបានធ្វើដោយប្រើប្រាស់អត្រាអប្បហារ (Discount Rate) ៥% ដើម្បីកែតំរូវទៅនឹង តម្លៃបច្ចុប្បន្ននៃឆ្នាំ ១៩៩៧ ។ លទ្ធផលដែលត្រូវបានបង្ហាញនៅតារាងទី ៤ ទី ៥ ខាង ក្រោម ។

## *១.ទិដ្ឋភាពទី១*

នៅទសវត្សក្រោយ អ្នកស្លាប់ដែលបង្កដោយថ្នាំជក់នៅកម្ពុជា នឹងសុទ្ធតែជាអ្នកពេញវ័យក្នុងឆ្នាំការងាររបស់ខ្លួន ។ ទិដ្ឋភាពទី១ (ឬទិដ្ឋភាពករណីមូលដ្ឋាន)គឺជាការសន្មតិដែលមានគំនិតទុទិដ្ឋិនិយម ។ គេសន្មតិថាគ្មានការការពារប្រកបដោយប្រសិទ្ធភាព និងគ្មានការប្រែប្រួលអាកប្បកិរិយាជក់ឡើយ ហើយគ្មានកំរិតកំពូល (ចំណុចដែលការជក់ថយចុះ) ក្នុងរយៈពេល ១០ឆ្នាំឡើយ ។ លទ្ធផលត្រូវបានបង្ហាញក្នុងតារាងទី ៤ ។

*តារាងទី ៤ ការប៉ាន់ស្មានទិដ្ឋភាពទី១*

| Year | Deaths | Accum. Death | Disc. Year | GDP(PPP) | Indirect Costs | Revenue | Balance |
|---|---|---|---|---|---|---|---|
| 1997 | 5,800 | 5,800 | 15.00 | 1266 | 110,142,000 | 52,000,000 | -58,142,000 |
| 1998 | 5,962 | 11,762 | 14.25 | 1266 | 107,564,677 | 53,456,000 | -54,108,677 |
| 1999 | 6,129 | 17,892 | 13.54 | 1266 | 105,047,664 | 54,952,768 | -50,094,896 |
| 2000 | 6,301 | 24,193 | 12.86 | 1266 | 102,589,548 | 56,491,446 | -46,098,103 |
| 2001 | 6,477 | 30,670 | 12.22 | 1266 | 100,188,953 | 58,073,206 | -42,115,747 |
| 2002 | 6,659 | 37,329 | 11.61 | 1266 | 97,844,531 | 59,699,256 | -38,145,276 |
| 2003 | 6,845 | 44,174 | 11.03 | 1266 | 95,554,969 | 61,370,835 | -34,184,135 |
| 2004 | 7,037 | 51,211 | 10.48 | 1266 | 93,318,983 | 63,089,218 | -30,229,765 |
| 2005 | 7,234 | 58,445 | 9.95 | 1266 | 91,135,319 | 64,855,716 | -26,279,603 |
| 2006 | 7,436 | 65,881 | 9.45 | 1266 | 89,002,752 | 66,671,676 | -22,331,076 |
| 2007 | 7,645 | 73,526 | 8.98 | 1266 | 86,920,088 | 68,538,483 | -18,381,605 |
| Total | 73,526 | | | | 1,079,309,486 | 659,198,605 | -420,110,881 |

ដោយគ្មានការការពារប្រកបដោយប្រសិទ្ធភាពនៅចុងឆ្នាំ ២០០៧ នឹងមាន :

-មនុស្សស្លាប់សរុប ៧៣.៥២៦នាក់

-តម្លៃខាតបង់ប្រយោលដល់សេដ្ឋកិច្ច ១.០៧៩លានដុល្លា ធៀបនឹងចំណូលតែ ៦៥៩លានដុល្លា ដែលធ្វើឱ្យខាតបង់ ៤២០លាន ដុល្លាដល់សេដ្ឋកិច្ច ។




## ២.ទិដ្ឋភាពទី២

ទិដ្ឋភាពទី២មានលក្ខណៈសុទិដ្ឋិនិយមបន្តិច ។ គេសន្មតិថានឹងគ្មានការការពារប្រកបដោយប្រសិទ្ធភាពទេ ប៉ុន្តែមានការប្រែប្រួលអាកប្បកិរិយាខ្លះនៅទសវត្សក្រោយៗ ដោយសារចំនួនអ្នកស្លាប់កើនឡើងត្រូវបានគេមើលឃើញជាក់ស្តែង ។ ការរាលដាលនឹងមានចំណុចកំពូលនៅឆ្នាំ ២០០៣ ។ ការប៉ាន់ស្មាននៃតំលៃនានាត្រូវ បានបង្ហាញ ក្នុងតារាង ៥ ។

*តារាងទី ៥ ការប៉ាន់ស្មានតាមទិដ្ឋភាពទី២*

| Year | Deaths | Accum. Death | Disc. Year | GDP(PPP) | Indirect Costs | Revenue | Balance |
|---|---|---|---|---|---|---|---|
| 1997 | 5,800 | 5,800 | 15.00 | 1266 | 110,142,000 | 52,000,000 | -58,142,000 |
| 1998 | 5,962 | 11,762 | 14.25 | 1266 | 107,564,677 | 53,456,000 | -54,108,677 |
| 1999 | 6,129 | 17,892 | 13.54 | 1266 | 105,047,664 | 54,952,768 | -50,094,896 |
| 2000 | 6,301 | 24,193 | 12.86 | 1266 | 102,589,548 | 56,491,446 | -46,098,103 |
| 2001 | 6,477 | 30,670 | 12.22 | 1266 | 100,188,953 | 58,073,206 | -42,115,747 |
| 2002 | 6,659 | 37,329 | 11.61 | 1266 | 97,844,531 | 59,699,256 | -38,145,276 |
| 2003 | 6,845 | 44,174 | 11.03 | 1266 | 95,554,969 | 61,370,835 | -34,184,135 |
| 2004 | 6,654 | 50,828 | 10.48 | 1266 | 88,235,459 | 59,652,452 | -28,583,007 |
| 2005 | 6,467 | 57,295 | 9.95 | 1266 | 81,476,623 | 57,982,183 | -23,494,440 |
| 2006 | 6,286 | 63,581 | 9.45 | 1266 | 75,235,513 | 56,358,682 | -18,876,832 |
| 2007 | 6,110 | 69,691 | 8.98 | 1266 | 69,472,473 | 54,780,639 | -14,691,834 |
| Total | 69,691 | | | | 1,033,352,411 | 624,817,465 | -408,534,946 |

ដោយគ្មានការ ការពារប្រកបដោយប្រសិទ្ធភាពទេ ប៉ុន្តែមានការប្រែប្រួលឥរិយាបទនៅចុងឆ្នាំ ២០០៧ នឹង មាន :

-ចំនួនអ្នកស្លាប់សរុប ៦៩.៦៩១នាក់ ។ មានន័យថា មាននាក់ស្លាប់ថយចុះ ៣.៨៣៥នាក់ និងតំលៃបង់ខាតថយចុះ ៨៦លានដុល្លា បើប្រៀបទៅនឹងទិដ្ឋភាពទី១ ។

-តំលៃបង់ខាតប្រយោលទៅលើសេដ្ឋកិច្ចមាន ១.០៣៣លានដុល្លាធៀបនឹងចំណូលតែ៦២៦លានដុល្លា ដែលធ្វើឱ្យខាតបង់ ៤០៨លានដុល្លាដល់សេដ្ឋកិច្ច ។




## ៣.ទិដ្ឋភាពទី៣

ដើម្បីពិនិត្យជំរើសមួយមានលក្ខណៈសុទិដ្ឋិនិយមជាងមុន ។ ទិដ្ឋភាពទី៣សន្មតថានឹងមានការប្រឹងប្រែងប្រកបដោយ ប្រសិទ្ធភាព ដើម្បីការពារការរាលដាល និងបង្កឱ្យមានការប្រែប្រួលដ៏ធំនៃអាកប្បកិរិយាដែលមានចំណុចកំពូលនៅឆ្នាំ ២០០០ ។ ហេតុផលចំពោះការសន្មតនេះ គឺថាក្រោយការចាប់ផ្តើមនៃការប្រឹងប្រែង ដ៏ខ្លាំងក្លាពីរដ្ឋនៅប្រទេសអភិវឌ្ឍន៍ ចំណុចកំពូលនៃការរាលដាលបានថយចុះជាងការរំពឹងទុកទៅទៀត ។ លទ្ធផលនៃការប៉ាន់ស្មានត្រូវបានបង្ហាញក្នុងតារាងទី៦ ។

*តារាងទី ៦ ការប៉ាន់ស្មានតាមទិដ្ឋភាពទី ៣*

| Year | Deaths | Accum. Death | Disc. Year | GDP(PPP) | Indirect Costs | Revenue | Balance |
|---|---|---|---|---|---|---|---|
| 1997 | 5,800 | 5,800 | 15.00 | 1266 | 110,142,000 | 52,000,000 | -58,142,000 |
| 1998 | 5,962 | 11,762 | 14.25 | 1266 | 107,564,677 | 53,456,000 | -54,108,677 |
| 1999 | 6,129 | 17,892 | 13.54 | 1266 | 105,047,664 | 54,952,768 | -50,094,896 |
| 2000 | 6,301 | 24,193 | 12.86 | 1266 | 102,589,548 | 56,491,446 | -46,098,103 |
| 2001 | 6,125 | 30,317 | 12.22 | 1266 | 94,731,189 | 54,909,685 | -39,821,504 |
| 2002 | 5,953 | 36,270 | 11.61 | 1266 | 87,474,780 | 53,372,214 | -34,102,566 |
| 2003 | 5,786 | 42,057 | 11.03 | 1266 | 80,774,212 | 51,877,792 | -28,896,420 |
| 2004 | 5,624 | 47,681 | 10.48 | 1266 | 74,586,907 | 50,425,214 | -24,161,693 |
| 2005 | 5,467 | 53,148 | 9.95 | 1266 | 68,873,550 | 49,013,308 | -19,860,242 |
| 2006 | 5,314 | 58,462 | 9.45 | 1266 | 63,597,836 | 47,640,935 | -15,956,901 |
| 2007 | 5,165 | 63,627 | 8.98 | 1266 | 58,726,242 | 46,306,989 | -12,419,253 |
| Total | 63,627 | | | | 954,108,605 | 570,446,350 | -383,662,256 |

ដោយមានការការពារដ៏មានប្រសិទ្ធភាព និងមានកាកែប្រែឥរិយាបទដ៏ធំធេងនៅចុងឆ្នាំ ២០០៧ នឹងមាន :

-ចំនួនមនុស្សស្លាប់សរុប ៦៣.៦២៧នាក់ ។ នេះមានន័យថា មានចំនួនមនុស្សស្លាប់ថយចុះ ៩.៨៩៩នាក់ និងថ្លៃខាតបង់ថយចុះ ១២៥លានដុល្លា បើធៀបនឹងទិដ្ឋភាពទី ១ ។

-តំលៃខាតបង់ប្រយោលទៅលើសេដ្ឋកិច្ចគឺ ៩៥៤លានដុល្លា ធៀបនឹងចំណូលតែ ៥៧០លានដុល្លា ដែលធ្វើឱ្យបង់ខាត ៣៨៣លានដុល្លា ដល់សេដ្ឋកិច្ច ។




## ៦.សេចក្ដីសន្និដ្ឋាន

ទោះបីជាមានការខ្វះខាតទិន្នន័យអំពីជម្ងឺដែលបង្កដោយបារីក៏ដោយ គេប៉ាន់ស្មានថា ការប្រើប្រាស់ថ្នាំជក់នៅកម្ពុជាមានផលប៉ះពាល់ដ៏ធំទៅលើគ្រួសារ និងសេដ្ឋកិច្ចជាតិផងដែរ ។ ការរាលដាលនៃបារីនឹងធ្វើឱ្យដំណើរការសេដ្ឋកិច្ចប្រែប្រួល ពីស្ថានភាពដើមប្រសិនបើគ្មានការរាលដាលទេ ។ ថ្លៃខាតបង់ប្រយោលដែលប៉ាន់ស្មានក្នុងអត្ថបទនេះ គឺគ្រាន់តែជាផ្នែកមួយក្នុងថ្លៃខាតបង់ដែលរំពឹងនានាដែលបណ្ដាលមកពីគ្រោះថ្នាក់នៃ ថ្នាំជក់ប៉ុណ្ណោះ ។ គុណភាពនៃពលកម្មអាចថយចុះដោយសារជម្ងឺដែលបង្កដោយផ្សែងបារី បន្ថយភាពសកម្ម និងភាពអត់ធ្មត់ក្នុងការងារ ។ ប្រាក់សន្សំគ្រួសារអាចថយចុះ ដោយគេចំណាយលើការថែទាំសមាជិកគ្រួសារដែលឈឺ ។ ទុនវិនិយោគសរុបរបស់ប្រទេសជាតិអាចកាន់តែចុះខ្សោយ ដោយសាររដ្ឋាភិបាលត្រូវចំណាយកាន់តែច្រើនទៅលើសេវាសុខាភិបាលសង្គម ដើម្បីកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចដោយការរាលដាលជំនួស ការដាក់ទុនទៅលើការបង្កើតផលិតកម្ម ។

ជាទូទៅ គេមិនអាចទប់ស្កាត់ថ្នាំជក់ទាំងស្រុងបានទេ ។ តែទោះជាយ៉ាងណាក៏ដោយរាជរដ្ឋាភិបាលត្រូវតែ គិតគូរពិចារណាសមស្របដើម្បីការពារ ឬយ៉ាងហោចណាស់បន្ថយការប្រើប្រាស់ថ្នាំជក់ ដើម្បីឱ្យប្រជាជនមាន សុខភាពកាន់តែប្រសើរឡើង និងសន្សំចំណូលឱ្យបានច្រើនដើម្បីចំណាយចំពោះអ្វីផ្សេងទៀត ដែលបានចំណេញ ជាងប្រើប្រាស់ថ្នាំជក់ ។

អ្នកផ្ដល់ជំនួយអន្តរជាតិគួរតែជួយក្នុងការកសាងសមត្ថភាព ដោយផ្ដល់ជំនួយបច្ចេកទេសដល់ទីភ្នាក់ងាររដ្ឋាភិបាល ដើម្បីរៀបចំកម្មវិធីគ្រប់គ្រងថ្នាំជក់ប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា ។ សកម្មភាពគ្រប់គ្រងថ្នាំជក់ គឺជាដំណើការមួយដែលទាមទារឱ្យពេលវេលាវែងឆ្ងាយ ដែលទាមទារការប្រឹងប្រែងច្រើនពីសំណាក់ទីភ្នាក់ងាររដ្ឋាភិបាល និងប្រជាជន ដើម្បីបុព្វហេតុនៃថ្នាំជក់ ឬសុខភាព ។ ការអប់រំសុខភាព គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពបំផុតដើម្បីត្រួតពិនិត្យថ្នាំជក់ ។

## ៧_សំណូមពរ

### ៧.១ យុទ្ធនាការគ្រប់គ្រងថ្នាំជក់

"ទិវាពិភពលោកគ្មានថ្នាំជក់" ឬ"ទិវាជាតិគ្មានថ្នាំជក់" គួរតែលើកទឹកចិត្តនិងបន្ត ។ សកម្មភាពនានាដូចជា ការសំដែងសិល្បៈ ការប្រកួតប្រជែងកំណាព្យ ។ល។ គួរតែរៀបចំក្នុងយុទ្ធនាការដើម្បីទទួលបាននូវការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋ ។

### ៧.២ ការអប់រំសុខភាព ឬការលើកកំពស់យល់ដឹង

យើងប្រហែលជាមិនអាចអូសទាញប្រជាជនចាស់ៗឱ្យយល់ពីគ្រោះថ្នាក់នៃការជក់ថ្នាំបានច្រើនឡើយ ប៉ុន្តែយើងមិនអាចអប់រំមនុស្សជំនាន់ក្រោយៗ ឱ្យយល់ពីផលប៉ះពាល់នៃថ្នាំជក់ ។ ការអប់រំសុខភាពគួរតែត្រូវបានដាក់ចូលក្នុង សាលារៀន និងកម្មវិធីកុមារក្នុងទូរទស្សន៍ ។ ផ្លាកចាំណូនៃការបង្ហាញពីគ្រោះថ្នាក់នៃបារី ដូចជា"ការជក់បារី សំលាប់" "ការជក់បារីធ្វើឱ្យខូចសុខភាព" ។ល។ ដែលគួរតែដាក់តាំងជិតចាំណូផ្សាយពាណិជ្ជកម្មបារី ។

### ៧.៣ គោលនយោបាយថ្លៃ (ពន្ធ, ពន្ធលើតំលៃបន្ថែម)

រដ្ឋាភិបាលគួរយកពន្ធលើថ្នាំជក់ឱ្យបានតឹងតែង ដោយតំឡើងពន្ធលើតំលៃបន្ថែម VAT ឬ ខិតខំទប់ស្កាត់ការគេចពន្ធ ។ វិធានការនេះអាចទប់ស្កាត់ការជក់ថ្នាំ ដើម្បីជួយសន្សំសំចៃចំណូលគ្រួសារ និងដើម្បីជួយ គ្រួសារបណ្តប់ថ្លៃបង់ខាតដែលបង្កដោយមរណភាពមុនអាយុ ដែលធ្វើឱ្យបាត់បង់ផ្លាំផលិតជាច្រើនឆ្នាំ ។

### ៧.៤ និតិកម្ម

ទីកន្លែងសាធារណៈខ្លះៗដូចជាមន្ទីរពេទ្យ ការិយាល័យប្រៃសណីយ៍ ការិយាល័យធ្វើការ រថយន្តក្រុង សាលប្រជុំ គួរតែពង្រឹងដោយច្បាប់ថា ជាកន្លែងហាមជក់ ។ នរណាដែលល្មើសនឹងផ្លាកបំរាម គួរតែផាកពិន័យដោយគ្មានអនុគ្រោះ ។

### ៧.៥ ស្ថាប័នសំរបសំរួល

មកទល់ពេលនេះ ការគ្រប់គ្រងថ្នាំជក់ស្ថិតនៅតែក្នុងក្រសួងសុខាភិបាលប៉ុណ្ណោះ ។ ដើម្បីឱ្យមានអំណាចកាន់ តែខ្លាំង និងដើម្បីសំរបសំរួលការងារឱ្យកាន់តែប្រសើរឡើង ស្ថាប័នសំរបសំរួលមួយដែលមានលក្ខណៈជាអន្តរក្រសួង គួរតែបង្កើតឡើងដូចជា "ក្រុមប្រឹក្សាជាតិស្តី ពីកាជក់ថ្នាំ និងសុខភាព" (ដូចប្រទេសន័រវេសដែលបានតែងតាំងនៅឆ្នាំ១៩៧១)[11] "គណកម្មាធិការគ្រប់គ្រងថ្នាំជក់" ឬ "គណកម្មាធិការប្រឆាំងការជក់បារី" គួរតែបង្កើតឡើងដើម្បី គ្រប់គ្រងថ្នាំជក់ ។

## REFERENCES


1- ADRA, Cambodian Tobacco or Health Program, Phnom Penh Cambodia, 1996
2- ADRA, Peoples Survey on smoking and legislation, May 1997
3- Bartechi C, Mackenzie T, Schreir R. The Human Cost of Tobacco. New England Journal of Medicine, 1994; Part I, 907-12, Part II, 975-80
4- Charles N. Myers, et al. Economic Cost of AIDS in Cambodia: Some Preliminary Estimates, UNDP Phnom Penh, 1997
5- Global Report on Tobacco or Health, Country Profile, 1997
6- Howard Barnum, Tobacco Control Winter 1994, Vol. 3, No.4, Pages 358- 361, The Economic Burden of the Global Trade in Tobacco, 1995
7- Judith Mackay, Report on National Tobacco Control Policy in Cambodia, 1997
8- Marion Merrell Dow Inc., Medical Information Services, Inc. The Economic Impact of Smoking on Wound Healing and Recovery from Surgery, 1991
9- Marion Merrell Dow Inc., Medical Information Services, Inc. The Economic Impact of Smoking on Infants and Children, 1991
10- Ministry of Health & WHO, Report on Tobacco Control Legislation Workshop on Tobacco Control Law in Cambodia, 3- 4 June 1997
11- Nigel Gray and Michael Daube, UICC, International Union Against Cancer, Guidelines for Smoking Control, Second Edition, 1980
12- Rockville, MD, US Department of Health and Human Services, Reducing the health consequences of smoking, 25 Years of Progress: A Report of the Surgeon General, 1989
13- Richard Peto, et al., Mortality from Smoking in Developed Countries, 1950-2000, 1994
14- SPRING 1995 Vol. 4 No. 1, An International Journal, Tobacco Control,
15- UICC, Tobacco Control Fact Sheets 5, Tobacco- The need for Alternative Economic Policies, A New Series of Fact Sheets From the International Union Against Cancer, 1993
16- UICC, Tobacco Control Fact Sheets, Series No. 2, A New Series of Fact Sheets From the International Union Against Cancer, 1996
17- WHO, Regional Office for the Western Pacific, Action Plan on Tobacco or Health for 1995- 1999, 1995


## COMPOSITION OF AUTHORS/TEAM


*1-* *Chap Sotharith*: Economist, Economic Advisor to the Co-Minister in charge of the Office of Council of Ministers.

*2-* *Lim Thai Pheang*, MD, Director, National Center for Health Promotion, Ministry of Health

*3-* *Po Samnang*: MD, MRDM, Deputy Chief of Health Education Office, National Center for Health Promotion, Ministry of Health